# បេឡាជាតិរបបសន្តិសុខសង្គម

## NATIONAL SOCIAL SECURITY FUND

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០១៧
## និងទិសដៅការងារឆ្នាំ២០១៨ របស់ក្រុមការងារ ស.ផ.ក





សកម្មភាព
ក្រុមការងារ ស.ផ.ក









# រចនាសម្ព័ន្ធក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់ គាំពារកម្មករនិយោជិត (ស.ផ.ក)



ឯកឧត្តម អ៊ុក សមវិទ្យា
ប្រធាន



លោកវេជ្ជបណ្ឌិត នាង ភារិទ្ធ
អនុប្រធាន



លោក ព្រាប ច័ន្ទវិបុល
អនុប្រធាន



លោក ឧត្តមសេនីយ៍ទោ លុយ ឈីន
អនុប្រធាន



លោក ហាក់ ហួលីម
សមាជិក



លោក សោម អូន
សមាជិក



លោកស្រី បុប្ផា ផានី
សមាជិក



ឯកឧត្តម ជាវ ប៊ុន រិទ្ធ
សមាជិក



លោកជំទាវ មុំ ចន្ទី
សមាជិក



លោកវរសេនីយ៍ទោ ភួង ម៉ាលី
សមាជិក



លោក គង់ អាទិត្យ
សមាជិក



លោក កាំង ម៉ូនីកា
សមាជិក



លោក យឹង រិទ្ធី
សមាជិក



លោកស្រី ឃុន ចាន់ផា
សមាជិក



លោក ឈួន វ៉ន់
សមាជិក



លោក ចាយ សំណាង
លេខាធិការ

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........ ១

១. ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ ........ ១

១.១ ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស ........ ១

១.២ ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត ........ ២

១.៣ គ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយគិតតាមប្រភេទ ........ ៤

១.៤ គ្រោះថ្នាក់ចរាចរណ៍តាមវិស័យ ........ ៥

១.៥ មូលហេតុគ្រោះថ្នាក់ចរាចរណ៍ (យានយន្តបង្ក) ........ ៥

២. លទ្ធផលការងារ ........ ៦

២.១ ប្រជុំក្រុមការងារ ........ ៦

២.២ ប្រជុំអប់រំផ្សព្វផ្សាយ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ........ ៧

២.៣ ការបណ្តុះបណ្តាល ប្រឡង ផ្តល់បណ្ណ ........ ៨

២.៤ ប្រឡង ផ្តល់បណ្ណបើកបរ ........ ៩

២.៥ ចុះចែកបណ្ណបើកបរ ........ ១០

២.៦ បំពាក់បដាពាក្យស្លោកស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ........ ១១

២.៧ បណ្តុះបណ្តាលគ្រូបង្គោលស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ........ ១១

២.៨ បណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋម ........ ១១

២.៩ ចែកបណ្ណមូលនិធិសមធម៌សុខាភិបាល ........ ១២

២.១០ ធ្វើបច្ចុប្បន្នភាពចំនួនយានយន្តដឹកកម្មករនិយោជិត ........ ១៣

៣. បញ្ហាប្រឈម ........ ១៣

៤. ដំណោះស្រាយ ........ ១៤

៥. សកម្មភាពការងារឆ្នាំ២០១៨ ........ ១៥

៦. សេចក្តីសន្និដ្ឋាន ........ ១៧

៧. សម្ភារឧបទ្ទេសសម្រាប់អប់រំផ្សព្វផ្សាយ ........ ១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨
# របស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក
# សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក)

## សេចក្តីផ្តើម

គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកជាបញ្ហាប្រឈមដ៏ធំមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកមិនអាចជៀសផុតបានឡើយ ប៉ុន្តែបញ្ហាប្រឈមនេះយើងអាចកាត់បន្ថយ និងការពារបាន។ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក គឺជាឃាតករលាក់មុខដែលធ្វើឱ្យមនុស្សស្លាប់ របួស និងពិការ ព្រមទាំងបានបន្សល់ទុកនូវសោកនាដកម្មដ៏រន្ធត់ ដែលជាផលប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចសង្គមទាំងមូល។ បញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនេះមិនអាចឱ្យ ក្រសួង ស្ថាប័ន ឬផ្នែកណាមួយធ្វើការទប់ស្កាត់ កាត់បន្ថយ ឬលុបបំបាត់បានឡើយ ប៉ុន្តែយើងអាចសហការគ្នាទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនេះ ឱ្យថយចុះមកនូវកម្រិតទាបបំផុត។

ក្នុងនោះសុវត្ថិភាពចរាចរណ៍ផ្លូវគោក គឺជាគោលដៅសំខាន់មួយនៃយុទ្ធសាស្ត្រ ប.ស.ស គឺធ្វើយ៉ាងណាជម្រុញការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យនៅកម្រិតទាបបំផុតនៅក្នុងឆ្នាំ២០១៨ ។

## ១. ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍

### ១.១ ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស

យោងលើទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស របស់ក្រសួងមហាផ្ទៃ (គិតចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧) បានកើតឡើងចំនួន **៣.៨១៥ លើក**[1] បណ្តាលឱ្យស្លាប់ចំនួន **១.៩១៣**នាក់ របួសធ្ងន់ចំនួន **៣.៦៦១ នាក់** និងរបួសស្រាលចំនួន **២.២៩១** នាក់ ។




*ប្រភព៖ រូបភាព គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក*

1 ប្រភពនាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ

មូលហេតុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍រួមមាន៖ ការបើកបរហួសល្បឿនកំណត់ ៤០% មិនគោរពសិទ្ធិអាទិភាព ១៤% មិនប្រកាន់ស្តាំ ១១% បត់ឆ្វេង-ស្តាំមិនប្រយ័ត្ន ១១% ជែងក្នុងស្ថានភាពគ្រោះថ្នាក់ ១០% ស្រវឹង ៨% កត្តាយានយន្ត ២% សុខភាពងងុយដេក ១% កត្តាផ្សេងៗ ៣% ។

**១.២ ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត**

គ្រោះថ្នាក់ចរាចរណ៍ប្រចាំឆ្នាំ២០១៧ បានកើតឡើងចំនួន **១.៧៧១លើក**[2] (គ្រោះថ្នាក់ដោយរថយន្តចំនួន **៩២លើក** (ក្នុងនោះ **២៦លើក** យានយន្តដឹកកម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ផលិតស្បែកជើង) ម៉ូតូចំនួន **១.៥៤០លើក** រ៉ឺម៉កចំនួន **១៦លើក** កង់ចំនួន **២៤ លើក** អ្នកថ្មើរជើងចំនួន **៦៥លើក** និង ផ្សេងៗ ចំនួន **៣៤លើក**) ជនរងគ្រោះសរុបចំនួន **២.៣២៦ នាក់** បណ្តាលឱ្យស្លាប់ចំនួន **៣៦នាក់** របួសធ្ងន់ ចំនួន **៣២០នាក់** និងរបួសស្រាលចំនួន **១.៩៧០នាក់** ។



*រូបភាព៖ គ្រោះថ្នាក់ចរាចរណ៍របស់រថយន្តដឹកកម្មករនិយោជិត នៅស្រុកបាទី ខេត្តតាកែវ*

ប្រៀបធៀបរយៈពេលដូចគ្នាឆ្នាំ២០១៦ ធៀបនឹងឆ្នាំ២០១៧ ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍មានការថយចុះចំនួន **៣.៨៣៨លើក** ស្មើនឹង **៦៨%** ជនរងគ្រោះថយចុះចំនួន **៥.១២០នាក់** ស្មើនឹង **៦៩%** ស្លាប់ថយចុះ ចំនួន **៦៧នាក់** ស្មើនឹង **៦៥%** របួសធ្ងន់ថយចុះចំនួន **៦៥០នាក់** ស្មើនឹង **៦៧%** និងរបួសស្រាលថយចុះចំនួន **៤.៤០៣នាក់** ស្មើនឹង **៦៩%** ។



*រូបភាព៖ គ្រោះថ្នាក់ចរាចរណ៍របស់រថយន្តដឹកកម្មករនិយោជិត នៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ*

2 ប្រភពរបាយការណ៍បេឡាជាតិរបបសន្តិសុខសង្គម

មូលហេតុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍រួមមាន៖ ការបើកបរហួសល្បឿនកំណត់ កត្តាបច្ចេកទេសយានយន្ត ការជែងក្នុងស្ថានភាពគ្រោះថ្នាក់ មិនគោរពសិទ្ធិអាទិភាព ស្រវឹង មិនប្រកាន់ស្តាំ កត្តាផ្លូវថ្នល់ និងកត្តាផ្សេងៗ ។

**តារាងប្រៀបធៀបចំនួនគ្រោះថ្នាក់ចរាចរណ៍កម្មករនិយោជិត ឆ្នាំ២០១៦ និងឆ្នាំ២០១៧**

| ល.រ | បរិយាយ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | កើនឡើង ឬថយចុះ | |
|---|---|---|---|---|---|
| | | | | ចំនួន | ភាគរយ |
| ០១ | លើក | ៥.៦០៩ | ១.៧៧១ | ៣.៨៣៨ | ៦៨% |
| ០២ | ជនរងគ្រោះសរុប(នាក់) | ៧.៤៤៦ | ២.៣២៦ | ៥.១២០ | ៦៩% |
| ០៣ | ស្លាប់(នាក់) | ១០៣ | ៣៦ | ៦៧ | ៦៥% |
| ០៤ | របួសធ្ងន់(នាក់) | ៩៧០ | ៣២០ | ៦៥០ | ៦៧% |
| ០៥ | របួសស្រាល(នាក់) | ៦.៣៧៣ | ១.៩៧០ | ៤.៤០៣ | ៦៩% |






### ១.៣ គ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយគិតតាមប្រភេទ

មធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិត ត្រូវបានបែងចែកជា **៦ប្រភេទ** រួមមាន៖ ការធ្វើដំណើរតាមរថយន្ត ម៉ូតូ រ៉ឺម៉ក កង់ អ្នកថ្មើរជើង និងមធ្យោបាយផ្សេងៗ។ ក្នុងចំណោមគ្រោះថ្នាក់ចំនួន **១.៧៧១លើក** គ្រោះថ្នាក់ដោយអ្នកប្រើប្រាស់ម៉ូតូមានចំនួន **១.៥៤០លើក** រថយន្តចំនួន **៩២លើក** រ៉ឺម៉កចំនួន **១៦លើក** កង់ចំនួន **២៤លើក** អ្នកថ្មើរជើងចំនួន **៦៥លើក** និងដោយមធ្យោបាយផ្សេងៗចំនួន **៣៤លើក** ។

| តារាងគ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយគិតតាមប្រភេទ | | |
|---|---|---|
| **ល.រ** | **បរិយាយ** | **ចំនួន (លើក)** |
| ០១ | ម៉ូតូ | **១.៥៤០** |
| ០២ | រថយន្ត | **៩២** |
| ០៣ | រ៉ឺម៉ក | **១៦** |
| ០៤ | កង់ | **២៤** |
| ០៥ | អ្នកថ្មើរជើង | **៦៥** |
| ០៦ | ផ្សេងៗ | **៣៤** |
| សរុប | | **១.៧៧១** |



### ១.៤ គ្រោះថ្នាក់ចរាចរណ៍តាមវិស័យ

គ្រោះថ្នាក់ចរាចរណ៍មកលើកម្មករនិយោជិត ក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងចំនួន **៩៥២លើក** វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុចំនួន **២៧៦លើក** និងវិស័យផ្សេងៗចំនួន **៥៤៣លើក** ។

| តារាងគ្រោះថ្នាក់ចរាចរណ៍តាមវិស័យ | | |
|---|---|---|
| **ល.រ** | **បរិយាយ** | **ចំនួន (លើក)** |
| ០១ | វិស័យកាត់ដេរសម្លៀកបំពាក់និងផលិតស្បែកជើង | **៩៥២** |
| ០២ | វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ | **២៧៦** |
| ០៣ | វិស័យផ្សេងៗ | **៥៤៣** |
| សរុប | | **១.៧៧១** |




### ១.៥ មូលហេតុគ្រោះថ្នាក់ចរាចរណ៍ (យានយន្តបង្ក)

គ្រោះថ្នាក់ចរាចរណ៍ដែលបង្កឡើងដោយយានយន្តដទៃមានចំនួន **៩៤៩លើក** ស្មើនឹង **៥៤%** និងបង្កឡើងដោយយានយន្តរបស់កម្មករនិយោជិតចំនួន **៨២២លើក** ស្មើនឹង **៤៦%** ។

| តារាងមូលហេតុគ្រោះថ្នាក់ចរាចរណ៍(យានយន្តបង្ក) | | | |
|---|---|---|---|
| **ល.រ** | **បរិយាយ** | **ចំនួន (លើក)** | **ភាគរយ** |
| ០១ | គ្រោះថ្នាក់ដែលបង្កឡើងដោយយានយន្តដទៃ | **៩៤៩** | **៥៤%** |
| ០២ | គ្រោះថ្នាក់ដែលបង្កឡើងដោយយានយន្តកម្មករនិយោជិត | **៨២២** | **៤៦%** |
| សរុប | | **១.៧៧១** | **១០០%** |



## ២. លទ្ធផលការងារ

### ២.១ ប្រជុំក្រុមការងារ

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បាន ប្រជុំក្រុមការងារ ចំនួន ៩លើក ដូចខាងក្រោម៖

- លើកទី១ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧ ពិភាក្សាលើរបៀបវារៈចំនួន ០២ គឺ៖
  - ពិនិត្យកែសម្រួលខ្លឹមសារសេចក្តីព្រាងរបាយការណ៍លទ្ធផលការងារសម្រេចបានត្រីមាសទី១ ឆ្នាំ២០១៧
  - បញ្ហាផ្សេងៗ ។
- លើកទី២ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ពិភាក្សាលើរបៀបវារៈចំនួន ០២គឺ៖
  - សេចក្តីព្រាងរបាយការណ៍លទ្ធផលការងារ សម្រេចបានឆមាសទី១ របស់ក្រុមការងារ ស.ផ.ក
  - បញ្ហាផ្សេងៗ ។
- លើកទី៣ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ ពិភាក្សាលើរបៀបវារៈចំនួន ០៣គឺ៖
  - ពិនិត្យពិភាក្សា និងកែសម្រួលផែនការឆមាសទី២ ឆ្នាំ២០១៧ របស់ក្រុមការងារ ស.ផ.ក
  - ខ្លឹមសារស្ពតអប់រំអំពីការកំណត់ល្បឿនសម្រាប់ទោចក្រយានយន្ត
  - បញ្ហាផ្សេងៗ ។
- លើកទី៤ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ បន្តពិភាក្សាលើរបៀបវារៈចំនួន ០៣គឺ៖
  - ពិនិត្យពិភាក្សា និងកែសម្រួលផែនការឆមាសទី២ ឆ្នាំ២០១៧ របស់ក្រុមការងារ ស.ផ.ក
  - ខ្លឹមសារស្ពតអប់រំអំពីការកំណត់ល្បឿនសម្រាប់ទោចក្រយានយន្ត
  - បញ្ហាផ្សេងៗ ។
- លើកទី៥ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ពិភាក្សាលើរបៀបវារៈចំនួន ០២គឺ៖
  - នីតិវិធីនៃការបណ្តុះបណ្តាល និងប្រឡងផ្តល់បណ្ណបើកបរ ជូនដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត
  - បញ្ហាផ្សេងៗ ។
- លើកទី៦ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ពិភាក្សាលើរបៀបវារៈចំនួន ០២គឺ៖
  - ពិនិត្យកែសម្រួលអំពីយន្តការកាត់បន្ថយចំនួនកម្មករនិយោជិតដែលជិះលើយានយន្តដឹកកម្មករ និងវិធានការទប់ស្កាត់ការផ្ទុកលើដំបូល និងឈរតោងរយីងរយោង
  - បញ្ហាផ្សេងៗ ។
- លើកទី៧ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ ពិភាក្សាលើរបៀបវារៈចំនួន ០២គឺ៖
  - បូកសរុបរបាយការណ៍លទ្ធផលការងាររយៈពេល ០៩ខែ ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត របស់ក្រុមការងារ ស.ផ.ក
  - បញ្ហាផ្សេងៗ ។
- លើកទី៨ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ ពិភាក្សាលើរបៀបវារៈចំនួន ០២គឺ៖
  - ពិនិត្យពិភាក្សា និងកែសម្រួលលើខ្លឹមសារសេចក្តីព្រាងខិត្តបណ្ណស្តីពីសុវត្ថិភាពចរាចរណ៍

- បញ្ហាផ្សេងៗ ។

➢ លើកទី៩ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ពិភាក្សាលើរបៀបវារៈចំនួន ០២គឺៈ

- ពិនិត្យកែសម្រួលអំពីយន្តការកាត់បន្ថយចំនួនកម្មករនិយោជិតដែលជិះលើយានយន្តដឹកកម្មករ និងវិធានការទប់ស្កាត់ការផ្ទុកលើដំបូល និងឈរតោងរយីងរយោង
- បញ្ហាផ្សេងៗ ។



*រូបភាពៈ ប្រជុំផ្ទៃក្នុងរបស់ក្រុមការងារ ស.ផ.ក ឆ្នាំ២០១៧*

## ២.២ ប្រជុំអប់រំផ្សព្វផ្សាយ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

### ២.២.១ ប្រជុំអប់រំផ្សព្វផ្សាយ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់កម្មករនិយោជិត

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បានប្រជុំអប់រំផ្សព្វផ្សាយ បានចំនួន **៣៩៣លើក** ដែលមានអ្នកចូលរួមសរុបចំនួន **៦០.៦៧៧នាក់** នៅរាជធានីភ្នំពេញ ខេត្តស្វាយរៀង តាកែវ កំពង់ចាម កំពង់ឆ្នាំង ព្រះសីហនុ កណ្តាល កំពង់ស្ពឺ កំពត ត្បូងឃ្មុំ និងខេត្តកោះកុង ។



*រូបភាពៈ ផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់កម្មករ*

### ២.២.២ ប្រជុំអប់រំផ្សព្វផ្សាយ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បានប្រជុំអប់រំផ្សព្វផ្សាយ បានចំនួន **២៤៩លើក** ដែលមានអ្នកចូលរួមសរុបចំនួន **២៧.៨៤០នាក់** នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កណ្តាល តាកែវ ព្រះសីហនុ កំពត កំពង់ចាម ស្វាយរៀង កំពង់ឆ្នាំង បន្ទាយមានជ័យ និងខេត្តព្រៃវែង ។




*រូបភាព៖ ផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរយានយន្តដឹកកម្មករ*



*រូបភាព៖ ផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត*

### ២.៣ បណ្តុះបណ្តាល ប្រឡង ផ្តល់បណ្ណបើកបរ

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បានសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន ចុះបណ្តុះបណ្តាលប្រឡងផ្តល់បណ្ណបើកបរ បានចំនួន **២៧លើក** ដែលមានអ្នកចូលរួមចំនួន **១.៣៧២នាក់** នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តតាកែវ។



*រូបភាព៖ បណ្ដុះបណ្ដាលច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ត្រៀមប្រឡងយកបណ្ណបើកបរ*



*រូបភាព៖ បំប៉នដៃចង្កូត ត្រៀមប្រឡងយកបណ្ណបើកបរ*

### ២.៤. ប្រឡងផ្ដល់បណ្ណបើកបរ

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បាន សហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន បានចុះប្រឡង ផ្ដល់បណ្ណបើកបរ ជូនអ្នកបើកបរយានយន្តដឹកកម្មករ បានចំនួន **៣លើក** មានសិក្ខាកាមចូលរួមចំនួន **២៥៨ នាក់ ជាប់ជាស្ថាពរចំនួន ២០១នាក់ នៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម។**



*រូបភាព៖ ការប្រឡងវិញ្ញាសារផ្នែកទ្រឹស្ដី*



*រូបភាព៖ ការប្រឡងវិញ្ញាសារផ្នែកដៃចង្កូត*

## ២.៥ ចុះចែកបណ្ណបើកបរ

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បាន ចុះចែកបណ្ណបើកបរ ដល់អ្នកបើកបរយានយន្តដឹកកម្មករបានចំនួន ៨លើក ដែលមានអ្នកទទួលបណ្ណ ចំនួន **៦៨៤នាក់** នៅខេត្តស្វាយរៀង កំពង់ចាម តាកែវ ព្រះសីហនុ និងខេត្តកំពង់ឆ្នាំង។



*រូបភាព៖ សកម្មភាពចែកបណ្ណបើកបរ ដល់អ្នកបើកបរយានយន្តដឹកកម្មករ*

## ២.៦. បំពាក់បដាពាក្យស្លោកស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បាន ចុះបំពាក់បដាពាក្យស្លោកស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានចំនួន **១៣១ផ្ទាំង** តាមបណ្តារោងចក្រ ដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ តាកែវ កំពង់ស្ពឺ ព្រះសីហនុ កំពង់ឆ្នាំង ស្វាយរៀង កណ្តាល និងខេត្តកំពង់ចាម។



*រូបភាព៖ សកម្មភាពចុះបំពាក់បដាពាក្យស្លោក*

## ២.៧. បណ្តុះបណ្តាលគ្រូបង្គោលស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បាន សហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន រៀបចំវគ្គ បណ្តុះបណ្តាលគ្រូបង្គោលស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ជូនរដ្ឋបាលរោងចក្រ ប្រតិភូបុគ្គលិក និង សហជីពមូលដ្ឋានបានចំនួន **០១លើក** អ្នកចូលរួមសរុបចំនួន**៥៥នាក់** នៅតំបន់សេដ្ឋកិច្ចពិសេស តាយសេង ក្រុងបាវិត ខេត្តស្វាយរៀង សម្រាប់ផ្សព្វផ្សាយបន្ត ដល់អ្នកបើកបរដឹកកម្មករនិយោជិត និងកម្មករនិយោជិត ឱ្យយល់ដឹងអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សុវត្ថិភាពដឹកជញ្ជូន និងសុវត្ថិភាព ធ្វើដំណើររបស់កម្មករនិយោជិត។



*រូបភាព៖ សកម្មភាពបណ្តុះបណ្តាលគ្រូបង្គោលចរាចរណ៍*

## ២.៨. បណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋម

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បាន សហការជាមួយកាកបាទក្រហមកម្ពុជា បានចុះបណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋម ដល់បុគ្គលិក

រដ្ឋបាលរោងចក្រ ប្រតិភូបុគ្គលិក សហជីពមូលដ្ឋាន និងគ្រូពេទ្យតាមរោងចក្រ បានចំនួន **០១លើក** អ្នកចូលរួមចំនួន **៣២នាក់** នៅបេឡាជាតិរបបសន្តិសុខសង្គម រាជធានីភ្នំពេញ សម្រាប់ជួយផ្សព្វផ្សាយបន្តដល់កម្មករនិយោជិតពេលមានគ្រោះថ្នាក់ មុនពេលរថយន្តសង្គ្រោះបន្ទាន់មកដល់ និងផ្សព្វផ្សាយដល់ក្រុមការងារក្នុងរោងចក្រ និងក្រុមគ្រួសាររបស់ពួកគាត់ ។



*រូបភាព៖ សកម្មភាពបណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋម*

### ២.៩. ចែកបណ្ណមូលនិធិសមធម៌សុខាភិបាល និងបណ្ណសម្គាល់យានយន្ត ចេញ-ចូល រោងចក្រ

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានសហការ ជាមួយអង្គការ ស្ថាប័នពាក់ព័ន្ធរៀបចំកម្មវិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល បានចំនួន ១៥៧បណ្ណ និងបណ្ណសម្គាល់យានយន្ត ចេញ-ចូលរោងចក្រ បានចំនួន **១៩៥បណ្ណ** ដែលមានទីតាំងនៅខេត្តកណ្តាល។



*រូបភាព៖ សកម្មភាពចែកបណ្ណមូលនិធិសមធម៌សុខាភិបាល*

២.១០. ចុះធ្វើបច្ចុប្បន្នភាពចំនួនយានយន្តដឹកកម្មករនិយោជិតទូទាំងប្រទេស ឆ្នាំ២០១៧ បានចំនួន **៤.៥២០គ្រឿង** ក្នុងនោះមានរថយន្តចំនួន **៤.២៣៩គ្រឿង** (រថយន្តទេសចរណ៍ចំនួន **១.២២៨គ្រឿង** និងរថយន្តដឹកទំនិញចំនួន **៣.០១១គ្រឿង**) និងរ៉ឺម៉កចំនួន **២៨១គ្រឿង**។





*រូបភាព៖ សកម្មភាពចុះស្រង់ស្ថិតិអ្នកបើកបរយានយន្តដឹកកម្មករ*

**៣. បញ្ហាប្រឈម**

- អ្នកបើកបរយានយន្តដឹកកម្មករ ២២% ពុំទាន់មានបណ្ណបើកបរ
- អ្នកបើកបរយានយន្តដឹកកម្មករមួយចំនួនតិចពុំមានបណ្ណបើកបរមិនតាមប្រភេទយានយន្ត
- អ្នកបើកបរយានយន្តដឹកកម្មករមួយចំនួន ពុំទាន់មានចំណេះដឹងគ្រប់គ្រាន់ ដើម្បីប្រឡងយកបណ្ណបើកបរ តាមរយៈប្រព័ន្ធកុំព្យូទ័រ
- មធ្យោបាយដឹកជញ្ជូនកម្មករមួយចំនួន មិនបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត
- មធ្យោបាយដឹកជញ្ជូនកម្មករមួយចំនួន ជាប្រភេទយានយន្តដឹកទំនិញ
- មធ្យោបាយដឹកជញ្ជូនកម្មករមួយចំនួន ពុំមានកៅអីអង្គុយឱ្យបានសមរម្យ
- មធ្យោបាយដឹកជញ្ជូនកម្មករភាគតិចនៅតែបន្តផ្ទុកលើសចំណុះ និងឈរតោងរយីងរយោងពីក្រោយ
- មានបញ្ហាកកស្ទះចរាចរណ៍នៅខាងមុខរោងចក្រមួយចំនួន ដោយមូលហេតុពុំមានចំណតសម្រាប់យានយន្តដឹកកម្មករ
- អ្នកបើកបរយានយន្តដឹកកម្មករមួយចំនួន ពុំសូវចេះច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- អ្នកបើកបរយានយន្តដឹកកម្មករភាគច្រើនមិនមានអ្នកគ្រប់គ្រងច្បាស់លាស់
- កម្មករនិយោជិតមួយចំនួន ជិះម៉ូតូពុំមានគ្រឿងបរិធានគ្រប់គ្រាន់
- កម្មករនិយោជិតមួយចំនួន ជិះម៉ូតូមិនពាក់មួកសុវត្ថិភាព ទាំងអ្នកបើកបរ និងអ្នករួមដំណើរ
- កម្មករនិយោជិតមួយចំនួន ពុំសូវចេះច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

- គ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដើម្បីផ្សព្វផ្សាយបន្តអំពីច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក ដល់កម្មករនិយោជិតនៅមានចំនួនតិច
- ការផ្សព្វផ្សាយបន្តអំពីចំណេះដឹងជំនាញសង្គ្រោះបឋមដល់កម្មករនិយោជិតនៅមានចំនួនតិច។
- ខ្វះជំរើសទឡានដែលមានសុវត្ថិភាពសម្រាប់កម្មករធ្វើដំណើរ និងតម្លៃសមរម្យ (លោក គង់ អាទិត្យ)

**៤. ដំណោះស្រាយ**

- សហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ចុះបណ្តុះបណ្តាល ប្រឡងផ្តល់បណ្ណបើកបរជូនអ្នកបើកបរយានយន្តដឹកកម្មករ ដែលមិនទាន់មានបណ្ណបើកបរ
- សហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ចុះបណ្តុះបណ្តាល ប្រឡងផ្តល់បណ្ណបើកបរជូនអ្នកបើកបរយានយន្តដឹកកម្មករ ដែលមានបណ្ណបើកបរមិនស្របតាមប្រភេទយានយន្ត
- សហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តដល់យានយន្តដឹកកម្មករ នៅតាមមូលដ្ឋានរោងចក្រប្រមូលផ្តុំ តំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហ-កម្ម........
- សហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី/ខេត្ត ដើម្បីជំរុញដល់អ្នកបើកបរយានយន្តដឹកកម្មករ ឱ្យយកយានយន្តទៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស នៅតាមស្ថានីយ៍ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត
- សហការជាមួយក្រសួង ស្ថាប័ន អង្គភាព សមត្ថកិច្ចពាក់ព័ន្ធ ជំរុញឱ្យអ្នកប្រើប្រាស់យានយន្តដឹកទំនិញ ប្តូរមកប្រើប្រាស់យានយន្តដឹកអ្នកដំណើរ ដើម្បីដឹកជញ្ជូនកម្មករនិយោជិត
- សហការជាមួយនាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការនគរបាលជាតិ និងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន ចុះត្រួតពិនិត្យឯកសារគតិយុត្តិរបស់អ្នកបើកបរយានយន្តដឹកកម្មករ (បណ្ណបើកបរ បណ្ណសម្គាល់យានយន្ត ឈៀក ពន្ធផ្លូវ បណ្ណអាជីវកម្ម...)
- ណែនាំដល់កម្មករ និងអ្នកបើកបរយានយន្តដឹកកម្មករ ពីហានិភ័យនៃការផ្ទុកលើសចំណុះ ឈរតោងក្នុងរថយន្ត ជិះលើដំបូល និងឈរតោងរយើងរយោងពីក្រោយរថយន្ត
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងរោងចក្រដើម្បីសម្រួលការកកស្ទះចរាចរណ៍ មុខរោងចក្រ
- ជំរុញឱ្យអ្នកបើកបរយានយន្តដឹកកម្មករ ដែលមានបណ្ណបើកបរប្រភេទ "ខ" ឬ "គ" ឱ្យចូលរៀនវគ្គបណ្តុះបណ្តាល ប្រឡងយកបណ្ណបើកបរប្រភេទ "ឃ២" ដើម្បីឱ្យស្របតាមប្រភេទយានយន្ត ដែលច្បាប់បានកំណត់
- សហការជាមួយក្រសួង ស្ថាប័ន អង្គភាព និងសមត្ថកិច្ចពាក់ព័ន្ធ ចុះអប់រំផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ផ្លាកសញ្ញា ភ្លើងសញ្ញា គំនូសសញ្ញា សិទ្ធិអាទិភាព ការបើកបរក្រោមឥទ្ធិពល

នៃគ្រឿងស្រវឹង គ្រឿងញៀន សុវត្ថិភាពធ្វើដំណើរ សុវត្ថិភាពដឹកជញ្ជូនកម្មករ ដល់អ្នកបើកបរយានយន្តដឹកកម្មករ និងកម្មករនិយោជិត

- បង្កើត និងជ្រើសរើសថ្នាក់ដឹកនាំ សមាគមអ្នកបើកបរយានយន្តដឹកកម្មករនិយោជិតប្រចាំរោងចក្រ តំបន់សេដ្ឋកិច្ចពិសេសសួនឧស្សាហកម្ម ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងអ្នកបើកបរយានយន្តដឹកកម្មករ
- សហការជាមួយរោងចក្រ ដើម្បីរៀបចំចំណតសម្រាប់យានយន្តដឹកកម្មករ
- ណែនាំ និងជំរុញដល់កម្មករនិយោជិត ដែលជិះម៉ូតូ ត្រូវបំពាក់គ្រឿងបរិធាន និងពាក់មួកសុវត្ថិភាពឱ្យបានត្រឹមត្រូវ ហើយត្រូវចូលរៀនច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (តាមកម្មវិធីរបស់ ប.ស.ស ដែលបានចុះបង្រៀននៅតាមរោងចក្រ ផ្ទះជួល និងបន្ទប់ជួលជាដើម)
- ជំរុញលើកទឹកចិត្តដល់គ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ ដើម្បីផ្សព្វផ្សាយបន្តឱ្យបានញឹកញាប់
- សហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចុះបណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅតាមរោងចក្រ
- សហការជាមួយក្រសួងសុខាភិបាល កាកបាទក្រហមកម្ពុជា ដើម្បីចុះបណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋមប្រចាំរោងចក្រ
- ស្រង់ស្ថិតិកម្មករនិយោជិតជិះម៉ូតូមិនពាក់មួកសុវត្ថិភាព ដើម្បីចាត់វិធានការអប់រំផ្សព្វផ្សាយអំពីការប្រើប្រាស់មួកស្តង់ដារសុវត្ថិភាពនិងចាត់វិធានការរដ្ឋបាល (ផាកពិន័យ) ដល់អ្នកមិនអនុវត្តច្បាប់
- ផ្តួចផ្តើមគំនិតបង្កើតតំបន់ដែលមានឡានក្រុងគំរូ ដែលមានសុវត្ថិភាពសម្រាប់កម្មករ និងគំនិតវិនិយោគជាមួយ និងការក្រុមវិនិយោគឯកជនជាតិ និងអន្តរជាតិ។ (លោក គង់ អាទិត្យ)

## ៥. សកម្មភាពការងារឆ្នាំ២០១៨

- សិក្សាស្រាវជ្រាវ វិភាគរកមូលហេតុថ្មីៗបន្ថែមទៀត ពីបញ្ហាគ្រោះថ្នាក់ចរាចរណ៍មកលើកម្មករនិយោជិត
- បន្តចុះអប់រំផ្សព្វផ្សាយអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសេចក្តីណែនាំលេខ០៦៦/១៧ របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ស្តីពីវិធានការថ្មីៗចំពោះអ្នកជិះ ទោចក្រយានយន្ត ដល់អ្នកបើកបរយានយន្តដឹកកម្មករ និងកម្មករនិយោជិត
- បន្តចាក់ផ្សាយវីដេអូអប់រំខ្លីៗ អំពីសុវត្ថិភាពចរាចរណ៍ ដល់អ្នកបើកបរយានយន្តដឹកកម្មករ និងកម្មករនិយោជិត តាមវិទ្យុ ទូរទស្សន៍
- បន្តផលិតវីដេអូអប់រំខ្លីៗ អំពីសុវត្ថិភាពចរាចរណ៍ដល់អ្នកបើកបរម៉ូតូ អំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកត្រង់ (មាត្រា៥-៣៣) ដើម្បីបង្ការគ្រោះថ្នាក់ចរាចរណ៍ដល់កម្មករនិយោជិត

- បន្តបោះពុម្ពបដាពាក្យស្លោកស្តីពីសុវត្ថិភាពចរាចរណ៍ អាវយឺត ខិត្តបណ្ណ សៀវភៅសុជីវធម៌ សៀវភៅច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ស្ទីគ័រកំណត់ល្បឿន ៤0Km/h និងស្ទីគ័រថ្ងៃនេះ និងថ្ងៃស្អែកកុំអោយមានគ្រោះថ្នាក់ចរាចរណ៍...........
- បន្តសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន ចុះបណ្តុះបណ្តាល ប្រឡងផ្តល់បណ្ណបើកបរ ដល់អ្នកបើកបរយានយន្ត ដឹកកម្មករនិយោជិត ដែលគ្មានបណ្ណបើកបរ
- បន្តសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន ចុះបណ្តុះបណ្តាល ប្រឡងផ្តល់បណ្ណបើកបរ ដល់អ្នកបើកបរយានយន្ត ដឹកកម្មករនិយោជិត ដែលមានបណ្ណបើកបរមិនស្របតាមប្រភេទយានយន្ត
- បន្តសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន បណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំរោងចក្រ
- សហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត សម្រាប់យានយន្តដឹកកម្មករ
- បន្តចែកបណ្ណមូលនិធិសមធម៌សុខាភិបាល និងបណ្ណសម្គាល់យានយន្តសម្រាប់ចេញ-ចូលរោងចក្រ ជូនអ្នកបើកបរយានយន្តដឹកកម្មករ
- ធ្វើបច្ចុប្បន្នភាពចំនួនអ្នកបើកបរ និងចំនួនយានយន្តដឹកកម្មករ (សម្រាប់ ឆ្នាំ២០១៨)
- បន្តចុះណែនាំ និងជំរុញឱ្យអ្នកបើកបរប្តូរពីប្រភេទយានយន្តដឹកទំនិញ មកប្រើប្រាស់ប្រភេទយានយន្តដឹកអ្នកដំណើរ
- បន្តចុះណែនាំ និងជំរុញដល់អ្នកបើកបរយានយន្តដឹកកម្មករ ឱ្យរៀបចំដាក់របាំងការពារនៅជញ្ជាំងរថយន្តឱ្យបានត្រឹមត្រូវ
- បន្តសហការជាមួយក្រសួងសុខាភិបាល និងកាកបាទក្រហមកម្ពុជា ចុះបណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋម ដល់រដ្ឋបាលរោងចក្រ ប្រតិភូបុគ្គលិក សហជីពមូលដ្ឋាន តំណាងកម្មករ និងអ្នកបើកបរយានយន្តដឹកកម្មករតាមមូលដ្ឋានរោងចក្រប្រមូលផ្តុំ
- បន្តបំពាក់ផ្ទាំងបដាពាក្យស្លោក ស្តីពីការអប់រំណែនាំអំពីសុវត្ថិភាពចរាចរណ៍ ដល់កម្មករនិយោជិត និងអ្នកបើកបរយានយន្តដឹកកម្មករ នៅតាមបណ្តារោងចក្រ
- បន្តបំពាក់ផ្ទាំងពាក្យស្លោកសីលធម៌១០ចំណុច ស្តីពីការអប់រំ ណែនាំអំពីសុវត្ថិភាពចរាចរណ៍ ដល់កម្មករនិយោជិត និងអ្នកបើកបរយានយន្តដឹកកម្មករ នៅតាមបណ្តារោងចក្រ
- ផ្តល់បណ្ណសរសើរដល់អ្នកបើកបរយានយន្តដឹកកម្មករដែលមានរយៈពេលយូរជាងគេ ហើយពុំដែលបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ និងមានឯកសារចរាចរណ៍គ្រប់គ្រាន់ភ្ជាប់តាមខ្លួន
- បន្តសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ចុះត្រួតពិនិត្យយានយន្តដឹកកម្មករ អំពីបណ្ណបើកបរ ផ្លាកលេខ ឈៀក (លក្ខណៈបច្ចេកទេសយានយន្ត)
- សហការជាមួយរោងចក្រ និងអាជ្ញាធររាជធានី/ខេត្ត រៀបចំចំណតសម្រាប់យានយន្តដឹកកម្មករ

- អនុវត្តភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់ថ្នាក់ដឹកនាំ។

## ៦. សេចក្តីសន្និដ្ឋាន

ជាលទ្ធផលទទួលបានជោគជ័យ ជាច្រើនតាមរយៈកិច្ចសហប្រតិបត្តិការណ៍ពហុវិស័យ និងមានការគាំទ្រដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ។ ជាមួយគ្នានោះដែរការទទួលការគាំទ្រពីដៃគូសហប្រតិបត្តិការជាតិ អន្តរក្រសួង ក្រុមហ៊ុនឯកជន ផ្នែកបច្ចេកទេស និងថវិកា បានធ្វើឱ្យសកម្មភាពគ្រប់ផ្នែកទាំងអស់របស់ ប.ស.ស មានដំណើរការរលូន និងមានប្រសិទ្ធិភាពជាងឆ្នាំមុនក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដល់កម្មករនិយោជិត ។ ទឡ្ហីកម្មទាំងនេះបានធ្វើឱ្យថ្នាក់ដឹកនាំ មន្ត្រីប.ស.ស កម្មករនិយោជិត មានការប្តេជ្ញាចិត្តខ្ពស់ស្មារតីប្រកបដោយភាពម្ចាស់ការ និងការទទួលខុសត្រូវក្នុងការបំពេញការងាររបស់ខ្លួនឱ្យកាន់តែប្រសើរឡើង និងកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា ។

## ៧. សម្ភារឧបទ្ទេសសម្រាប់ផ្សព្វផ្សាយអប់រំ រួមមាន ៖




*សៀវភៅច្បាប់ចរាចរណ៍ផ្លូវគោក*




*អនុក្រឹត្យស្តីពីការកំណត់ល្បឿនសម្រាប់យានជំនិះ*
*និងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក*







*អ្នកបើកបរទោចក្រយានយន្តត្រូវយល់ដឹង*




*កម្រងឯកសារ ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក*




*សីលធម៌១០ចំណុច  សម្រាប់សុវត្ថិភាពចរាចរណ៍*




សីលធម៌១០ចំណុច សម្រាប់សុវត្ថិភាពចរាចរណ៍




កុំបើកបរវែង ដោយប្រថុយ
បើបើកបរវែងដោយប្រថុយ អាចបណ្ដាលឱ្យមានគ្រោះថ្នាក់
N.R.S.C.
MINISTRY OF PUBLIC WORKS AND TRANSPORT
NSSF
National Social Security Fund
CAMBODIAN RED CROSS
១១៩ រថយន្តសង្គ្រោះបន្ទាន់
១២៨៦ លេខទូរស័ព្ទសង្គ្រោះបន្ទាន់របស់ ប.ស.ស
អត់មេរោគកំអាច
ហៅចូលបានដែរ


អ្នកបើកបរម៉ូតូ និងអ្នករួមដំណើរ
ត្រូវពាក់មួកសុវត្ថិភាព
បើមិនពាក់មួកសុវត្ថិភាព នឹងត្រូវពិន័យជាប្រាក់ ១៥ ០០០ រៀល
N.R.S.C.
MINISTRY OF PUBLIC WORKS AND TRANSPORT
NSSF
National Social Security Fund
CAMBODIAN RED CROSS
១១៩ រថយន្តសង្គ្រោះបន្ទាន់
១២៨៦ លេខទូរស័ព្ទសង្គ្រោះបន្ទាន់របស់ ប.ស.ស
អត់មេរោគកំអាច
ហៅចូលបានដែរ


អ្នកបើកបរ ត្រូវមានបណ្ណបើកបរ
តាមប្រភេទយាន
N.R.S.C.
MINISTRY OF PUBLIC WORKS AND TRANSPORT
NSSF
National Social Security Fund
CAMBODIAN RED CROSS
១១៩ រថយន្តសង្គ្រោះបន្ទាន់
១២៨៦ លេខទូរស័ព្ទសង្គ្រោះបន្ទាន់របស់ ប.ស.ស
អត់មេរោគកំអាច
ហៅចូលបានដែរ


កុំធ្វើជាឃាតករ
ដោយការបង្កគ្រោះថ្នាក់ចរាចរណ៍
N.R.S.C.
MINISTRY OF PUBLIC WORKS AND TRANSPORT
NSSF
CAMBODIAN RED CROSS
១១៩ រថយន្តសង្គ្រោះបន្ទាន់
១២៩៥ លេខទូរស័ព្ទសង្គ្រោះបន្ទាន់របស់ ប.ស.ស
អត់មវិកាក៏អាច
ហៅចូលបានដែរ


មុនចេញដំណើរ អ្នកបើកបរត្រូវត្រួតពិនិត្យ
កង់ ហ្វ្រាំង ចង្កូត និងភ្លើង
កុំប្រើសំបកកង់ផុះ និងហួសរយៈពេលប្រើប្រាស់
N.R.S.C.
MINISTRY OF PUBLIC WORKS AND TRANSPORT
NSSF
CAMBODIAN RED CROSS
១១៩ រថយន្តសង្គ្រោះបន្ទាន់
១២៩៥ លេខទូរស័ព្ទសង្គ្រោះបន្ទាន់របស់ ប.ស.ស
អត់មវិកាក៏អាច
ហៅចូលបានដែរ


គិតដល់ជីវិតអ្នក និងអ្នកដទៃ កុំផ្ទុកលើសចំណុះ
បើផ្ទុកលើសចំណុះនឹងត្រូវពិន័យជាប្រាក់ ១៥ ០០០ រៀល ដល់ ៧៥ ០០០ រៀល
N.R.S.C.
MINISTRY OF PUBLIC WORKS AND TRANSPORT
NSSF
CAMBODIAN RED CROSS
១១៩ រថយន្តសង្គ្រោះបន្ទាន់
១២៩៥ លេខទូរស័ព្ទសង្គ្រោះបន្ទាន់របស់ ប.ស.ស
អត់មវិកាក៏អាច
ហៅចូលបានដែរ


កុំជិះលើដំបូល និងកុំឈរតោង
ពីក្រោយរថយន្ត
១១៩ រថយន្តសង្គ្រោះបន្ទាន់
១២៨៦ លេខទូរស័ព្ទសង្គ្រោះបន្ទាន់របស់ ប.ស.ស
អត់មរិកាក៏អាច
ហៅចូលបានដែរ


បើពិសាគ្រឿងស្រវឹង កុំបើកបរ
បើមានជាតិអាល់កុលចាប់ពី ០,៤០មីលីក្រាមក្នុងមួយលីត្រខ្យល់ឡើងទៅ ត្រូវជាប់ពន្ធនាគារ
ពី១ខែ ដល់៦ខែ និងត្រូវពិន័យជាប្រាក់ ៤០ម៉ឺនរៀល ដល់ ៤លានរៀល
១១៩ រថយន្តសង្គ្រោះបន្ទាន់
១២៨៦ លេខទូរស័ព្ទសង្គ្រោះបន្ទាន់របស់ ប.ស.ស
អត់មរិកាក៏អាច
ហៅចូលបានដែរ


ត្រូវដឹកកម្មករតាមរថយន្តដឹកអ្នកដំណើរ
កុំយករថយន្តដឹកទំនិញមកដឹកកម្មករ
១១៩ រថយន្តសង្គ្រោះបន្ទាន់
១២៨៦ លេខទូរស័ព្ទសង្គ្រោះបន្ទាន់របស់ ប.ស.ស
អត់មរិកាក៏អាច
ហៅចូលបានដែរ


ពិធីផ្សព្វផ្សាយ
ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក សុវត្ថិភាពចរាចរណ៍
លើមធ្យោបាយដឹកជញ្ជូន ជូនដល់អ្នកបើកបរដឹកកម្មករនិយោជិត
(គម្រោងកម្មវិធីបង្ការគ្រោះថ្នាក់ការងារ ឆ្នាំ២០១៧)


ពិធីផ្សព្វផ្សាយ
ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក សុវត្ថិភាពចរាចរណ៍
លើមធ្យោបាយធ្វើដំណើរ ជូនដល់កម្មករនិយោជិត
(គម្រោងកម្មវិធីបង្ការគ្រោះថ្នាក់ការងារ ឆ្នាំ២០១៧)


វគ្គបណ្តុះបណ្តាលគ្រូបង្គោល
អំពីច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពធ្វើដំណើរ
របស់កម្មករនិយោជិត ជូនដល់រដ្ឋបាលរោងចក្រ ប្រតិភូបុគ្គលិក
និងបុគ្គលិកសហជីពមូលដ្ឋាន
សហការរៀបចំដោយ
ក្រសួងសាធារណការនិងដឹកជញ្ជូន
បេឡាជាតិរបបសន្តិសុខសង្គម
គម្រោងកម្មវិធីបង្ការគ្រោះថ្នាក់ការងារ ឆ្នាំ២០១៧


វគ្គបណ្តុះបណ្តាលច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
ប្រឡង និងផ្តល់បណ្ណបើកបរ ជូនដល់អ្នកបើកបរដឹកកម្មករនិយោជិត
នៅតាមមូលដ្ឋានរោងចក្រ ប្រមូលផ្តុំអ្នកបើកបរដឹកកម្មករនិយោជិត
សហការរៀបចំដោយ
MINISTRY OF PUBLIC WORKS AND TRANSPORT
ប.ស.ស
NSSF
National Social Security Fund
ក្រសួងសាធារណការនិងដឹកជញ្ជូន
បេឡាជាតិរបបសន្តិសុខសង្គម
គម្រោងកម្មវិធីបង្ការគ្រោះថ្នាក់ការងារ ឆ្នាំ២០១៧


ពិធីប្រជុំផ្សព្វផ្សាយអប់រំ
អំពីសុវត្ថិភាពចរាចរណ៍ លើមធ្យោបាយដឹកជញ្ជូន
និងពិធីប្រគល់បណ្ណបើកបរ ជូនដល់អ្នកបើកបរដឹកកម្មករនិយោជិត
សហការរៀបចំដោយ
MINISTRY OF PUBLIC WORKS AND TRANSPORT
ប.ស.ស
NSSF
National Social Security Fund
ក្រសួងសាធារណការនិងដឹកជញ្ជូន
បេឡាជាតិរបបសន្តិសុខសង្គម


វគ្គបណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋម
ជូនដល់រដ្ឋបាលរោងចក្រ ប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋាន
សហការរៀបចំដោយ
CAMBODIAN RED CROSS
ប.ស.ស
NSSF
National Social Security Fund
កាកបាទក្រហមកម្ពុជា
បេឡាជាតិរបបសន្តិសុខសង្គម
(គម្រោងកម្មវិធីបង្ការគ្រោះថ្នាក់ការងារ ឆ្នាំ២០១៧)

## របៀបនៃការពាក់មួកសុវត្ថិភាពត្រឹមត្រូវ



## ការជ្រើសរើសមួកសុវត្ថិភាពដែលមានគុណភាព(ស្តង់ដា)

### វិធីជ្រើសរើសមួកសុវត្ថិភាព



សំបក ៖ មានភាពរឹងមាំ រលោង និងផ្ទៃគ្របដណ្តប់ធំ
ទ្រនាប់ស្នោ ៖ មានកម្រាស់ ១,៥ ទៅ ៣សង់ទីម៉ែត្រ
ទ្រនាប់អេប៉ុង ៖ ស្រទាប់ទន់ផ្តល់ជាសុខភាព
កញ្ចក់ ៖ ថ្លាល្អដើម្បីមើលឃើញច្បាស់
ខ្សែទ្រចង្កា ៖ ជាប់មាំល្អ
ពណ៌ ៖ ពណ៌មានចំណាំង
ទំហំ ៖ ល្មមនឹងក្បាល

### ស្តង់ដាមួកសុវត្ថិភាព

ស្តង់ដាមួកសុវត្ថិភាពនៃប្រទេសមួយចំនួន

| ប្រទេស | ប្រទេស |
|---|---|
| វៀតណាម | TCVN5756:2001 |
| ថៃ | TIS 369-2539 |
| ម៉ាឡេស៊ី | MS-1:1996 |
| សហរដ្ឋអាមេរិក | DOT 218 |
| ឥណ្ឌូនេស៊ី | SNI 1811-2007 |
| កម្ពុជា | CS 105:2010 |

សញ្ញាស្តង់ដាទាំងនេះមានជាប់នៅលើមួកសុវត្ថិភាព

**ថ្ងៃនេះ ថ្ងៃស្អែក កុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍**

## គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
## ជំនួយស្មារតីស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកសម្រាប់ផ្សព្វផ្សាយ
## ប្រការសំខាន់ៗដែល ត្រូវចងចាំចំពោះអ្នកប្រើប្រាស់ផ្លូវ

### I. ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

### ១. អ្នកជិះកង់ និងថ្មើរជើង ៖

- ✓ អ្នកជិះកង់ ត្រូវជិះអែបកៀកខាងស្តាំបំផុត និងត្រូវធ្វើការបត់ឆ្វេង ដោយប្រុងប្រយ័ត្ន ឬបើចាំបាច់ត្រូវចុះបណ្តើរកង់ដូចថ្មើរជើងដែរ( បើពាក់មួកសុវត្ថិភាពរឹតតែជាការប្រសើរ )
- ✓ ថ្មើរជើង ត្រូវដើរលើចិញ្ចើម ឬជាយផ្លូវ។ បើពុំមានចិញ្ចើម ឬជាយផ្លូវត្រូវអែបកៀកខាងស្តាំបំផុត និងត្រូវឆ្លងកាត់នៅលើគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ បើពុំមានគំនូសសញ្ញាទេ ត្រូវឆ្លងកាត់តាមកែងទទឹងថ្នល់ដោយប្រុងប្រយ័ត្ន។

### ២. អ្នកជិះម៉ូតូ, ម៉ូតូកង់បី, ម៉ូតូសណ្តោងរ៉ឺម៉ក

#### ក. អ្នកបើកបរម៉ូតូ ត្រូវមាន ៖

- ✓ អ្នកបើកបរម៉ូតូ ដែលមានទំហំស៊ីឡាំងមិនលើសពី ១២៥សេសេ ត្រូវមានអាយុចាប់ពី ១៥ឆ្នាំឡើង និងត្រូវយកភ្ជាប់តាមខ្លួននូវ អត្តសញ្ញាណបណ្ណសម្គាល់ខ្លួន ឬលិខិតបញ្ជាក់អត្តសញ្ញាណដែលមានតម្លៃស្មើ
- ✓ អ្នកបើកបរម៉ូតូ ដែលមានទំហំស៊ីឡាំងចាប់ពី ១២៦សេសេឡើងទៅ ត្រូវភ្ជាប់តាមខ្លួននូវបណ្ណបើកបរប្រភេទ **ក**
- ✓ អ្នកបើកបរម៉ូតូកង់បី និងម៉ូតូសណ្តោងរ៉ឺម៉ក ត្រូវយកភ្ជាប់តាមខ្លួននូវបណ្ណបើកបរប្រភេទ **ក**

#### ខ. ម៉ូតូ ត្រូវមាន ៖

- ✓ បណ្ណសម្គាល់ម៉ូតូត្រូវយកភ្ជាប់តាមខ្លួន និងពាក់ផ្លាកលេខត្រឹមត្រូវ
- ✓ មានកញ្ចក់មើលក្រោយ កង់ល្អ ហ្វ្រាំងស៊ី ភ្លើង និងកញ្ចក់ចាំងពន្លឺត្រូវដំណើរការច្បាស់ល្អ

#### គ. ពេលបើកបរ ៖

- ✓ ត្រូវពាក់មួកសុវត្ថិភាពទាំងអ្នកបើកបរ និងអ្នករួមដំណើរព្រមទាំងកុមារដែលមានអាយុពី ៣ឆ្នាំឡើង
- ✓ ពេលចេញដំណើរត្រូវមើលឆ្វេងស្តាំ និងត្រូវប្រកាន់ស្តាំជានិច្ច
- ✓ គោរពសញ្ញាចរាចរណ៍( គំនូស ផ្លាក ភ្លើង និងសញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ )
- ✓ ល្បឿនអតិបរមា ក្នុងទីប្រជុំជន ៣០គ.ម/ម៉
- ✓ ល្បឿនអតិបរមាក្រៅទីប្រជុំជន ៤០គ.ម/ម៉ សម្រាប់ម៉ូតូកង់៣ និងម៉ូតូសណ្តោងរ៉ឺម៉ក ៦០គ.ម/ម៉ សម្រាប់ម៉ូតូត្រឹម ១២៥សេសេ និង ៧០គ.ម/ម៉ សម្រាប់ម៉ូតូលើស ១២៥សេសេ
- ✓ បើកបរមិនស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀន
- ✓ ត្រូវបន្ថយល្បឿន និងគោរពសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ

- ✓ ហាមផ្ទុកមនុស្ស ឬទំនិញលើសចំណុះ សំពីងសំពោង និងហាមប្រើទូរស័ព្ទដោយគ្មានឧបករណ៍ភ្ជាប់សម្លេង
- ✓ ត្រូវមានបំពង់ពន្លត់អគ្គីភ័យ និងសញ្ញាត្រីកោណផ្តល់ដំណឹង
- ✓ ត្រូវមានស្មារតីប្រុងប្រយ័ត្ន ចេះយោគយល់អធ្យាស្រ័យ

## II. សញ្ញាចរាចរណ៍

### ១. ភ្លើងសញ្ញា

- ➢ ភ្លើងពណ៌ក្រហម គឺជាសញ្ញាឃាត់ឱ្យឈប់ អ្នកបើកបរម៉ូតូ ឬអ្នកបើកបរម៉ូតូកង់បី ឬអ្នកបើកបរម៉ូតូសណ្តោង រ៉ឺម៉ក ឬរថយន្តត្រូវឈប់នៅមុខខ្សែបន្ទាត់គំនូសជាប់ពណ៌សកាត់ទទឹងទ្រូងផ្លូវ ឬមុខគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់ 
- ➢ ភ្លើងពណ៌លឿង គឺជាសញ្ញាប្រុងប្រយ័ត្ន ត្រៀមឈប់ 
- ➢ ភ្លើងពណ៌បៃតង ជាសញ្ញាអនុញ្ញាតឱ្យយានជំនិះចេញដំណើរ។ 

### ២.ផ្លាកសញ្ញា

| | | | |
|---|---|---|---|
|  | សញ្ញានេះហាមចូលចំពោះយានជំនិះគ្រប់ប្រភេទ |  | សញ្ញានេះហាមឈប់ចំពោះយានជំនិះគ្រប់ប្រភេទ |
|  | សញ្ញានេះ ហាមចូលចំពោះទោចក្រយានយន្ត |  | សញ្ញានេះ ហាមចតចំពោះយានជំនិះគ្រប់ប្រភេទ ប៉ុន្តែអ្នកបើកបរអាចឈប់ដាក់មនុស្ស ឬទំនិញឡើងចុះក្នុងរយៈពេលចាំបាច់ |
|  | សញ្ញានេះ ហាមជែងចំពោះយានយន្តគ្រប់ប្រភេទ លើកលែងតែទោចក្រយានយន្ត |  | សញ្ញានេះ ហាមស៊ីផ្លេចំពោះយានជំនិះគ្រប់ប្រភេទ លើកលែងតែករណីអាចមានគ្រោះថ្នាក់បន្ទាន់ |
|  | សញ្ញានេះ ចប់ការហាមជែងចំពោះយានយន្តគ្រប់ប្រភេទ |  | សញ្ញានេះ ហាមយានជំនិះគ្រប់ប្រភេទបត់ឆ្វេង |
|  | សញ្ញានេះ ហាមចូលចំពោះរថយន្តដឹកអ្នកដំណើរធុនធំ ដែលជាប្រភេទរថយន្តផ្ទុកអ្នកដំណើរលើសពី ២០នាក់ គិតទាំងអ្នកបើកបរ |  | សញ្ញានេះ ហាមយានយន្តគ្រប់ប្រភេទបើកបរលើសល្បឿនកំណត់(គីឡូម៉ែត្រក្នុង១ម៉ោង) ដូច មានកំណត់ក្នុងផ្លាកសញ្ញា |
|  | សញ្ញានេះ ហាមចូលចំពោះរថយន្តដឹកទំនិញធុនធ្ងន់ ដែលជាប្រភេទរថយន្តមានទម្ងន់សរុបអតិបរមាលើសពី ៣,៥តោន |  | សញ្ញានេះ ចប់ការហាមចំពោះយានយន្តគ្រប់ប្រភេទបើកបរលើសល្បឿន ដូចមានកំណត់ក្នុងផ្លាកសញ្ញា |

| | | | |
|---|---|---|---|
|  | សញ្ញានេះ សម្រាប់សម្គាល់ផ្លូវបាត់សិទ្ធិ។ អ្នកបើកបរ ត្រូវតែបន្ថយល្បឿន បើសិនផ្លូវទំនេរ អាចឆ្លងកាត់បាន។ |  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខអាចរអិល ពិសេសនៅពេលភ្លៀង។ |
|  | សញ្ញានេះ សម្រាប់សម្គាល់ផ្លូវបាត់សិទ្ធិ។ អ្នកបើកបរត្រូវឈប់ទោះបីមាន ឬគ្មានយានជំនិះផ្សេងទៀតឆ្លងកាត់នៅខាងមុខក៏ដោយ។ អ្នកបើកបរអាចបន្តដំណើរទៅមុខបាន លុះត្រាតែផ្លូវឆ្លងកាត់នោះទំនេរ។ |  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរប្រុងប្រយ័ត្ន ខាងមុខមានសត្វពាហនៈឆ្លងកាត់។ |
|  | សញ្ញានេះ សម្រាប់សម្គាល់ផ្លូវជំរួមតូចនៅខាងមុខ អាចធ្វើចរាចរណ៍បានតែមួយជួរ។ អ្នកបើកបរលើកំណាត់ផ្លូវដែលមានសញ្ញានេះ ត្រូវផ្តល់សិទ្ធិអាទិភាពឱ្យយានមកពីទិសផ្ទុយទៅមុន។ |  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរ ប្រុងប្រយ័ត្ន មានផ្លូវកោងស្តាំ ហើយកោងទៅឆ្វេងនៅខាងមុខ។ |
|  | សញ្ញានេះ ហាមយានជំនិះគ្រប់ប្រភេទបត់ត្រឡប់ក្រោយ។ |  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមានផ្លូវចុះចំណោត។ |
|  | សញ្ញានេះ សម្រាប់សម្គាល់ផ្លូវជំរួមតូចនៅខាងមុខអាចធ្វើចរាចរណ៍បានតែមួយជួរ។ អ្នកបើកបរលើកំណាត់ផ្លូវដែលមានសញ្ញានេះ មានសិទ្ធិអាទិភាពលើយានមកពីទិសផ្ទុយ។ |  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមានផ្លូវរួមតូច។ |
|  | សញ្ញានេះ តម្រូវឱ្យយានជំនិះគ្រប់ប្រភេទបត់បើកបរវាងក ឬវាងទៅស្តាំ។ |  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ដុំថ្មក្រាលលើផ្លូវ។ |
|  | សញ្ញានេះ តម្រូវឱ្យយានជំនិះគ្រប់ប្រភេទបត់ស្តាំនៅខាងមុខផ្លាកសញ្ញា។ |  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរប្រុងប្រយ័ត្ន ខាងមុខអាចមានកុមារឆ្លងកាត់។ |
|  | សញ្ញានេះ តម្រូវឱ្យយានជំនិះគ្រប់ប្រភេទបត់ស្តាំនៅត្រង់ផ្លូវប្រសព្វខាងមុខពីក្រោយផ្លាកសញ្ញា។ |  | សញ្ញានេះ ប្រើសម្រាប់បញ្ជាក់អំពីគ្រោះថ្នាក់ផ្សេងៗ ដែលគ្មានចែងនៅក្នុងប្រភេទសញ្ញាគ្រោះថ្នាក់។ |
|  | សញ្ញានេះ តម្រូវឱ្យយានជំនិះគ្រប់ប្រភេទបត់ស្តាំ ឬបត់ឆ្វេងនៅត្រង់ផ្លូវប្រសព្វខាងមុខ។ |  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរប្រុងប្រយ័ត្ន មានផ្លូវកោងបត់បែនច្រើនសានៅខាងមុខ។ |

| | | | |
|---|---|---|---|
|  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមានផ្លូវខ្វែង |  | គំនូសសញ្ញាទោល ជាប់ពណ៌លឿងតាមបណ្ដោយទ្រូងផ្លូវ ប្រើសម្រាប់បែងចែកទ្រូងផ្លូវជាពីរ ទិសចរាចរណ៍ផ្ទុយគ្នា និងហាមបើកបរជាន់ ឬឆ្លងកាត់ |
|  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរ ប្រុងប្រយ័ត្ន មានផ្លូវកោងទៅស្ដាំនៅខាងមុខ |  | គំនូសសញ្ញាទោលដាច់ៗពណ៌លឿង តាមបណ្ដោយទ្រូងផ្លូវ ប្រើសម្រាប់បែងចែកទ្រូងផ្លូវជាពីរទិសចរាចរណ៍ផ្ទុយគ្នា អ្នកបើកបរអាចឆ្លងកាត់ ឬជែងបាន |
|  | សញ្ញានេះ ប្រើសម្រាប់ឱ្យអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខអាចមានថ្មើរជើងឆ្លងកាត់ |  | គំនូសសញ្ញាភ្លោះពណ៌លឿង ដែលមានគំនូសដាច់ៗនៅខាងឆ្វេង និងគំនូសជាប់ខាងស្ដាំតាមបណ្ដោយទ្រូងផ្លូវប្រើសម្រាប់បែងចែកផ្លូវជាពីរ ទិសចរាចរណ៍ផ្ទុយគ្នា។ អ្នកបើកបរនៅកៀកគំនូសដាច់ៗ អាចឆ្លងកាត់ ឬជែងបាន ប៉ុន្តែអ្នកបើកបរនៅកៀកគំនូស ជាប់មិនអាចឆ្លងកាត់ ឬជាន់បានឡើយ។ |

**បញ្ជាក់៖**

- ការធ្វើលិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូន ធ្វើនៅអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន
- ការប្រឡងយកបណ្ណបើកបរ ត្រូវប្រលងនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត
- ការធ្វើផ្លាកលេខម៉ូតូ អាចទៅធ្វើនៅតាមច្រកចេញចូលតែមួយនៅតាមបណ្ដាក្រុង ស្រុក ខណ្ឌ ឬនៅតាមមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត

អាសយដ្ឋាន ៖

អគារលេខ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ( បរិវេណក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ)

ទូរស័ព្ទលេខ ៖

០២៣ ៨៨២ ៤៣៤ / ០២៣ ៨៨១ ០១៥

០២៣ ៨៨១ ០១៦ / ០២៣ ៨៨១ ០១៧




## សេវាសង្គ្រោះបន្ទាន់

## 1286

## Hotline 24/7

អ៊ីម៉ែល៖ info@nssf.gov.kh

គេហទំព័រ៖ Website: nssf.gov.kh

www.facebook.com/nssfpage